ព្រឹត្តិបត្រ ប្រចាំខែ

# អ្នកនាំសារ
THE MESSENGER

ពត៌មានពីព្រះសហគមន៍កាតូលិក | Internal Use | ឆ្នាំទី ០២ លេខ ១០ ខែ កុម្ភៈ ឆ្នាំ ២០០៤

# ការកសាងសង្គម និង ព្រះសហគមន៍ ជាថ្មីឡើងវិញនៅក្នុងប្រទេសកម្ពុជា

## ការកកើតព្រះសហគមន៍ជុំគិរី

នៅឆ្នាំ ១៩៩២ មានគ្រួសារមួយប្ដី ឈ្មោះ យិន ប៊ូ ប្រពន្ធឈ្មោះ ជូ អាន ដែលបាន ធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ ជំរំសាយបី មកតាំងទីលំក្នុងស្រុកជុំគិរីខេត្តកំពត។ គ្រួសារលោកពូជាគ្រីស្តបរិស័ទគាត់តែងអធិដ្ឋាន និងសំដែងសេចក្ដី ស្រឡាញ់ចំពោះអ្នកជិតខាង។ បន្តិចម្ដងៗមានមនុស្សជាច្រើនចង់ស្គាល់ និងឆ្ងល់ពីសកម្មភាពគ្រួសាររបស់លោក ពូ។ នៅឆ្នាំ ១៩៩២ ខែធ្នូ ក្នុងគ្រួសារនេះមានទុក្ខជាទំងន់លោកពូ យិន ប៊ូ ទទួលមរណៈភាពចោលប្រពន្ធនិងបន្សល់ទុកកូន៦នាក់រស់នៅយ៉ាងលំបាក។ ទោះជាយ៉ាងណាក៏ដោយអ្នកមីងនៅតែមានសេចក្ដីសង្ឃឹមជានិច្ចចំពោះព្រះជាម្ចាស់ដោយការអធិដ្ឋាន និងប្រតិបត្តិតាមព្រះបន្ទូល។

នៅឆ្នាំ ១៩៩២ អ្នកមីងបានមកទីក្រុងភ្នំពេញទាក់ទងនិងព្រះសហគមន៍ ព្រោះមានបងប្អូនខ្លះចង់ស្គាល់ព្រះជាម្ចាស់ ហើយអ្នកមីងបានអញ្ជើញលោកឪពុកដើម្បីទៅសួរសុខទុក្ខគេ។ នៅពេលនោះលោកឪពុកវិរៈជ័យ ជាអ្នកជាអ្នកជាអ្នកទទួលខុសត្រូវព្រះសហគមន៍ បានចុះសួរសុខទុក្ខគេពីរបីខែម្ដង។

តទៅទំព័រទី ៥




*ការធ្វើមាតុភូមិនិវត្តន៍ ឆ្នាំ ១៩៩២ (រូបភាព UN)*

ក្រោយពីសង្គ្រាមជិត២០ឆ្នាំ កន្លងមកនេះប្រទេសកម្ពុជាបានរកដំណោះស្រាយមួយដោយសន្តិវិធីដែលភាគីទាំងបីបានរួបរួមគ្នាតាមរយៈការចុះសន្ធិសញ្ញាសន្តិភាពនៅទីក្រុងប៉ារីសនៅឆ្នាំ ១៩៩១ ព្រមទាំងរៀបចំធ្វើមាតុភូមិនិវត្តន៍បងប្អូនដែលបានរត់គេចពីសង្គ្រាមទៅសុំសិទ្ធិជ្រកកោននៅប្រទេសថៃវិលត្រឡប់មកកាន់ប្រទេសវិញ និងបានរៀបចំការបោះឆ្នោតមួយ ប្រកបដោយសេរីយុត្តិធមនៅឆ្នាំ១៩៩៣ដើម្បីជ្រើសរើសរដ្ឋាភិបាលថ្មីរៀបចំប្រទេស ឡើងវិញ ដែលបានខ្ទេចខ្ទាំ

តទៅទំព័រទី ៤

## ព្រះសហគមន៍កើតថ្មីនៅភូមិភាគកំពង់ចាម

ព្រះសហគមន៍ក្ដីបឹងស្ថិតនៅភូមិក្ដីបឹង ស្រុកកំពង់ត្របែក ខេត្តព្រៃវែង (ភូមិភាគកំពង់ចាម) ។ ព្រះវិហារនេះស្ថិតនៅតំបន់ដាច់ស្រយាល ដែលបានកើតឡើងដោយសារលោកពូម្នាក់ឈ្មោះ ធឿន។ ពីមុនគាត់បានទៅរៀននៅសាលាសេដ្ឋកិច្ចជិតវត្តភ្នំទីក្រុងភ្នំពេញ បើតាមសំដីរបស់បងប្អូននៅទីនោះ។ គ្រាមួយពូធឿនមានជំងឺជាទម្ងន់ ហើយគ្មានលទ្ធភាពទៅ ព្យាបាលនៅមន្ទីរពេទ្យ។ គ្រានោះគាត់បានជួប ពូទ្រីធ្វើការបំរើអ្នកជំងឺក្នុងព្រះសហគមន៍ ហើយបាននាំគាត់ទៅមន្ទីរពេទ្យព្យាបាលរហូតជាសះស្បើយ។ ក្រោយមកគាត់បានត្រឡប់ទៅផ្ទះវិញដើម្បីរកការងារធ្វើ។

តទៅទំព័រទី ៥

# សេចក្តីថ្លែងការណ៍របស់ ព្រះសហគមន៍កាតូលិកកម្ពុជា

***

យើងជាគ្រីស្តបរិស័ទនៃព្រះសហគមន៍កាតូលិកកម្ពុជា

មានសេចក្តីសោកសង្រេង ដោយសោកស្តាយជាពន់ពេក

ចំពោះមរណៈភាពរបស់លោក **ជា វិជ្ជា** ដែលជាមនុស្សមានចិត្តក្លាហាន

ពុះពារគ្រប់ឧបសគ្គ ដើម្បីការពារអ្នកទន់ខ្សោយ រកយុត្តិធមអោយសង្គមជាតិ ។

ឃាតកម្មលើរូបលោក **ជា វិជ្ជា** គឺជាការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ

ដែលធ្វើអោយពន្លឺលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាអាប់រស្មីដោយសារអំពើរល្មើសច្បាប់នេះ ។

យើងខ្ញុំសូមថ្កោលទោសយ៉ាងដាច់អហង្កាចំពោះឧក្រិដ្ឋជនដែលបានប្រព្រឹត្តអំពើដ៏ព្រៃផ្សៃនេះមកលើមនុស្សស្លូតត្រង់ ។

សូមអោយគំរូនៃវីរភាពដ៏ថ្លៃថ្លារបស់លោក **ជា វិជ្ជា** ដិតជាប់ក្នុងក្រអៅបេះដូងនៃពលរដ្ឋខ្មែរគ្រប់រូប

សូមអោយមានជនកម្ពុជាកាន់តែច្រើនឡើង មានចិត្តក្លាហានដូចលោក **ជា វិជ្ជា** ។

យើងខ្ញុំសូមអធិដ្ឋានដល់ព្រះជាម្ចាស់ដែលយើងគោរពបូជា

សូមព្រះអង្គពាំនាំយកវិញ្ញាណក្ខន្ធលោក **ជា វិជ្ជា** ទៅនៅជាមួយព្រះអង្គឯស្ថានបរមសុខ

កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអោយប្រទេសកម្ពុជាបានប្រកបដោយសេចក្តីសុខសាន្ត យុត្តិធម៌ និង សេរីភាព ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៣ មករា ២០០៤

តំណាងគ្រីស្តបរិស័ទព្រះសហគមន៍កាតូលិកនៅកម្ពុជា

ហត្ថលេខា

ព្រះសហគមន៍កាតូលិក

ភូមិភាគភ្នំពេញ

អេមីល ដេតម្ប

*អភិបាល*

# Cambodian Catholic Community Statement

***

We, Christians of the Catholic Community,
want to express our strong regret and extreme sorrow for
the death of the prominent Union Leader Chea Vechea, a brave
man who overcame all kinds of obstacles to protect the weak and look for justice in our society.

The murder of Mr. Chea Vechea is a grave violation of human rights, due to the lack
of respect of the Laws which makes Cambodian Democracy
fall down into deep darkness.

We want to emphatically condemn the murderers who have committed such a brutal
crime on the honest Chea Vechea.
May the heroic example of Mr. Chea Vechea be in every heart of our Cambodian fellow citizens.
We wish Cambodian people had such as brave heart as Mr. Chea Vechea.

We ask the Lord to accept the soul of Mr. Chea Vechea so that
he may forever live in heaven with God.

May Cambodia always live in peace, justice and freedom.

Phnom Penh January 23, 2004
Representative of Christians of the Catholic Church

Singnature



**Apostolic Vicariate**
**of Phnom Penh**

**Emile Destombes**
**Bishop**

# ការកសាងសង្គម,,,

ដោយសារសង្គ្រាម និងដោយអំពើប្រល័យពូជសាសន៍ ដែលធ្វើអោយប្រទេសធ្លាក់ក្នុងភាពងងឹតសូន្យសុង។ ប៉ុន្តែនៅពេលនោះបងប្អូន ដែលបានត្រលប់ចូលមកកាន់ប្រទេសវិញមានការលំបាកជាច្រើនដូចជាគ្មានទីជំរកជីថ្លី ម្យ៉ាងទៀតបងប្អូនដែលនៅក្នុងស្រុកមិនសូវទទួលស្វាគមន៏ពួកគេប៉ុន្មានទេដោយចាត់ទុកថាអ្នកទាំងនោះរត់ចោលស្រុក។

ស្របពេលជាមួយគ្នានេះប្រទេសកម្ពុជាកំពុងរៀបចំកសាងឡើងវិញ ក៏មានអង្គការក្រៅរដ្ឋាភិបាលជាច្រើនបានចូលមកជួយដោយ មានបើកជាមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនិងសេវាសុខភាព។ ក្នុងពេលជាមួយគ្នានោះដែររដ្ឋាភិបាលបានផ្តល់សេរីភាព ដល់ប្រជាជនវិញ ទាំងសេរីភាពខាងសាសនាដែលបានចែងយ៉ាងច្បាស់ក្នុងរដ្ឋធម្មនុញ្ញ ហើយគ្រីស្តសាសនាក៏ចាប់ផ្តើមមាន ជីវិតសារជាថ្មីម្តងទៀតដែរ។ គ្រីស្តសាសនា បែកចេញនិកាយជាច្រើន មាននិកាយខ្លះបានធ្វើការប្រកាស ផ្សាយហួសហេតុដែលប៉ះពាល់ដល់ទំនៀមទំលាប់ ប្រពៃណីរបស់ខ្មែរ និងព្រះពុទ្ធសាសនា ធ្វើអោយអ្នកខ្លះយល់ច្រឡំ។តែទោះជាមានជួបឧបសគ្គ យ៉ាងណាក៏ដោយក៏នៅ



*ព្រះសហគមន៏ខ្នាចរមាស*

មានបងប្អូនជាច្រើនដែលចង់ស្វែងយល់ និងដើរតាមព្រះគ្រីស្ត រហូតរីកសាយភាយទៅដល់តំបន់ដាច់ស្រយាល ស្ទើរតែគ្រប់ទីកន្លែងនៅក្នុងប្រទេសទាំងមូល។

ព្រះសហគមន៏កើតមាននៅក្នុងប្រទេសកម្ពុជាតាំងពីសតវត្សទី ១៦មកម្លេះ។ ហើយក្នុងចំណោមប្រជាជនដែលធ្វើមាតុភូមិនិវត្តន៏មកពីប្រទេសថៃក៏មានមួយចំនួនជាគ្រីស្តបរិស័ទ គេរស់នៅដោយខិតខំប្រព្រឹត្តតាមព្រះបន្ទូល និងសំដែងសេចក្តីស្រឡាញ់ចំពោះបងប្អូន ដែលរស់នៅជិតខាងរហូតដល់កកើតមានជាព្រះសហកគមន៏នៅកន្លែងរបស់គេទៀតផងដែលមានការទទួលស្គាល់ពីលោកបូជាចារ្យដូចជានៅ បាត់ដំបង តាកែវ កំពត កំពង់ចាម ជាដើម។ ចាប់តាំងពីពេលនោះមកព្រះសហគមន៏ ចាប់ផ្តើមរីកចំរើនឡើងជាលំដាប់ រហូតដល់បច្ចុប្បន្ននេះដោយមានបងស្រី លោកបូជា ចារ្យ ស្ម័គ្រចិត្តមកជួយអភិវឌ្ឍន៏ផ្នែកសង្គម និងសាសនាដោយមានបើក ជាមណ្ឌលអប់រំផ្សេងៗ សំរាបយុវជនយុវនារី ។ជារៀងរាល់ឆ្នាំព្រះសហគមន៏ ក៏មានការប្រជុំ គណៈកម្មការ ព្រះសហគមន៏ ទូទាំងប្រទេស ដើម្បីរិះរកមធ្យោបាយអភិវឌ្ឍន៏គំរោង។ ជារៀងរាល់ថ្ងៃព្រះសហគមន៏ មានបង្កើតសម្មភាពផ្សេងៗ ដោយបង្ហាញសេចក្តីស្រឡាញ់ របស់ព្រះយេស៊ូគ្រីស្តចំពោះមនុស្សគ្រប់ជាតិសាសន៏ អោយគេយល់ពីធម៏មេត្តាករុណារបស់ព្រះអង្គ តាមរយៈ បងស្រីលោកឳពុក នឹង គ្រីស្តបរិស័ទ ទាំងអស់ ។ ព្រះសហគមន៏កំពុងតែបន្តដំណើរ ទៅមុខជានិច្ច ដែលមានព្រះវិញ្ញាណជួយណែនាំផ្លូវទៅកាន់ព្រះបិតា។ ចំពោះការ កើនឡើងនូវចំនួនព្រះសហគមន៏ជារៀងរាល់ឆ្នាំនេះគឺបណ្តាលមកពី ព្រះអំណោយទាន របស់ព្រះអង្គ ដែលបានសំដែងអោយមនុស្សលោកស្គាល់អំពីព្រះហឬទ័យមេត្តាករុណា និងបង្រួបបង្រួមមនុស្សជាមហា គ្រួសារតែមួយដែលពោរពេញ ដោយសេចក្តីស្រឡាញ់ដ៏ពិតប្រាកដមិនចេះ សាបសូន្យ។



*ព្រះសហគមន៏ចំការទៀង*

***លោកឳពុក ប៉ូល***

## ការកកើតព្រះសគមន៍ជុំគិរី


ពិធីជ្រមុជទឹកដល់បងប្អូននៅព្រះសហគមន៍ជុំគិរី

ពេលនោះប្រទេសយើងពុំ ទាន់មានសន្តិភាពពេញលេញនៅឡើយទេ គឺនៅមានភាពរកាំរកូសរវាងរដ្ឋាភិបាល និងខ្មែរក្រហម ។ហើយគេចេះតែរករឿងផ្សេងៗទាំងសាសនា និង នយោបាយ តែយ៉ាងណាក៏ដោយក៏មានមនុស្សជាច្រើនចូលចិត្តអ្នកមីង។ ដោយសេចក្តីស្រឡាញ់របស់ ព្រះជាម្ចាស់ ដែលមានចំពោះមនុស្សយ៉ាងលើសលប់ នោះធ្វើអោយមានបងប្អូនជាច្រើន ចង់ស្គាល់ព្រះហឫទ័យមេតាការុណារបស់ព្រះជាម្ចាស់ ។នៅឆ្នាំ ១៩៩៨ មាននិស្សិតទេវវិទ្យាល័យពីភ្នំពេញជួយអប់រំជំនឿដល់បងប្អូន រាល់ពីរសប្តាហ៍ម្តងរួមជាមួយអ្នកមីង ។ តាំងពីពេលនោះមកមានមនុស្ស ជាច្រើនចង់ស្គាល់ ចង់ដឹងពីព្រះបន្ទូលព្រះយេស៊ូ ។ ដោយផ្ទះអ្នកមីងតូចមិនអាចដាក់មនុស្សបានច្រើន លោកឪពុកវិរៈជ័យ បានសាងព្រះវិហារមួយដែលមានឈ្មោះថា សន្តយ៉ូសែប ។

នៅឆ្នាំ២០០១ព្រះសហគមន៍បានធ្វើពិធីសម្ពោធព្រះវិហារ និងមានបងប្អូនចំនួន ២០នាក់ដែលបានទទួលការអប់រំនជំនឿ ទទួលពិធីជំហានទី១ផង។ ហើយគេបានទទួលពិធីជ្រមុជទឹក នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៣ ។ នេះជាសញ្ញាសំគាល់អោយឃើញថាព្រះសហគន៏កំពុងរីកចំរើនឡើង ។ រៀងរាល់អាទិត្យមានមនុស្សពី ៤០ ទៅ ៦០នាក់ដែលបានមកជួបជុំគ្នា និងចូល រួមក្នុងអភិបូជាព្រមទាំងទទួលការអប់រំជំនឿមានលោកឪពុកលីជាអ្នកណែនាំ។

ឆ្នាំ២០០៣នេះព្រះសហគមន៍បាន រីកចំរើនឡើងជាលំដាប់ ដោយមានបើសាលាមត្តេយ្យសំរាប់អប់រំកុមារនៅតាមភូមិដែលមានចំនួន ២០នាក់កំពុងសិក្សារ។

ព្រះសហគមន៍បានកើតឡើងដោយសារគ្រួសារមួយសុខចិត្តរស់តាមជំនឿ ដូចព្រះបន្ទូលបានឆែងថា : " ព្រះរាជ្យព្រះជាម្ចាស់ប្រៀបបាននឹងគ្រាប់ពូជដំល្អិត ពេលវាដុះឡើងវានឹងក្លាយជាដើមឈើដ៏ធំជាងគេជាជម្រកដល់បក្សាបក្សីជ្រកអាស្រ័យនៅ " ។

*លោកឪពុក សួន ហង្ស លី*

## ព្រះសហគមន៏កើតថ្មីនៅ,,,,,,,

ពេលត្រលប់ទៅផ្ទះវិញមានអ្នកជិត ខាងមកសួរសុខទុក្ខ ហើយគាត់បានរៀបរាប់អំពីជីវិតរបស់គាត់នៅភ្នំពេញ។ ពូធឿន បានពន្យល់ពីការយកចិត្តទុកដាក់ពី ព្រះសហគន៏ បងស្រី និង ក្រុមសង្គហៈ ហើយបានរៀបរាប់អំពីជីវិតរបស់ លោកបូជាចារ្យ បងស្រី ដែលសុខចិត្តលះបង់ ប្រយោជន៏ផ្ទាល់ខ្លួនរស់នៅលីវអស់មួយជីវិត ដាក់ខ្លួនជាអ្នកក្រខ្សត់ បំរើអ្នកក្រីក្រ ក្មេងកំព្រា អ្នកជំងឺ អ្នកគ្មាន ទីពឹងដែលយកព្រះយេស៊ូជាគំរូស៊ូលះបង់ ជីវិតលើឈើឆ្កាង ព្រោះតែសេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះមនុស្ស។ ពេលបានស្តាប់ ឮដូច្នេះពួកគេចង់ស្គាល់ព្រះយេស៊ូដែលបានធ្វើការអស្ចារ្យចំពោះមនុស្សលោក អោយគេហ៊ានលះបង់ប្រយោជន៏ផ្ទាល់ខ្លួនសុខចិត្ត បំរើអ្នកដទៃ ។ បន្ទាប់មកមានមនុស្សជា ច្រើនចង់ដឹងចង់យល់ពីព្រះបន្ទូលព្រះជាម្ចាស់ ក៏ង្កើតបានក្រុមមួយមកជួបជុំគ្នានៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ។


ការជួបជុំរបស់បងប្អូនក្តីបឹង ព្រៃវែង

តាមសំដីរបស់លោកឪពុកអន់តូនី បានអោយដឹងថាៈ ថ្ងៃមួយលោកពូធឿនបានអញ្ជើញគ្រូគង្វាលម្នាក់ មកពីខាងប្រូតេស្តង់មកជួយ ណែនាំបងប្អូនទាំងនោះ តែគ្រូគង្វាលនោះមិនពេញចិត្តក៏ឈប់បង្រៀន បន្ទាប់មកបានទាក់ទងគ្រូគង្វាលម្នាក់ទៀតគេក៏រត់ចោល

តទៅទំព័រទី ៦

# វាចាអ្នកអាន

សូមជូនសួនកំណាព្យ បទកាកគតិ

- ជូនអ្នកនាំសារ ពីខ្ញុំនេះណា ជួយចុះផ្សាយផង នាទីកំណាព្យ
  ជូនអស់បងប្អូន ខុសត្រូវឆ្កាំឆ្គង សូមលោកមេត្តា ។
- ពេលដែលរូបខ្ញុំ នៅកំពង់ធំ អានអ្នកនាំសា ក្នុងចិត្តរំភើប
  រីករាយអស្ចារ្យ ពត៌មានខ្លឹមសារ ព្រះសហគមន៍ ។
- ពីពត៌មាន លេខប្រាំមួយមាន បេសកកម្ម ព្រះសហគមន៍
  ដែលបានណែនាំ កម្ពុជាយូរឆ្នាំ ដំណរមកហើយ ។
- ពីសាសនទូត ដែលមានរកូត ទាំងក្នុងទាំងក្រៅ គ្រប់ៗប្រទេស
  ដែលបានចុះទៅ នឹងបានរស់នៅ គ្រប់ទីកន្លែង ។
- ជួយអស់ប្រជា អ្នកម្ដាយតេរេសា គ្មានខ្លាចគិតក្រែង អោយតែប្រជា
  មានទុកជាក់ស្ដែង អ្នកម្ដាយយើងតែង ចុះជាប់ជានិច្ច ។
- តែងជួយសង្គ្រោះ ប្រជាទាំងអស់ ពុំមានភ្លាំងភ្លេច គ្រប់ទុក្ខលំបាក
  តែងបានសំរេច អ្នកម្ដាយប្ដូរផ្ដាច់ បំរើប្រជា ។
- ស្ត្រីមេម៉ាយ ពេលដែលអ្នកម្ដាយ ជួបទុក្ខវេទនា ទាំងអស់បងប្អូន
  កុមារកំព្រា ទាំងចាស់ជរា កំសត់ទុរគត ។
- នេះជាទឹកចិត្ត ដ៏ល្អប្រណិត ជួយអ្នកក្រខ្សត់ របស់អ្នកម្ដាយ
  តេរេសាកំណត់ ចុះគ្រប់ជនបទ មិនប្រកាន់សាសន៍ ។
- ក្នុងក្រៅប្រទេស វិជ្ជាចំណេះ ដែលជួបប្រទះ អ្នកម្ដាយតែងជួយ
  អប់រំតំរិះ វិជ្ជាចំណេះ ផុតភាពលង់ខ្លៅ ។
- ទឹកចិត្តអ្នកម្ដាយ ទោះលំបាកកាយ យ៉ាងណាក៏ត្រូវ អោយតែប្រជា
  សុខសាន្តរស់នៅ ដើម្បីជាផ្លូវ សុភមង្គលល្អ ។
- អ្នកម្ដាយតេរេសា ស្រុកទេសណាៗ ខ្ញុំថ្លែងអំណរ អរគុណអ្នកម្ដាយ
  ដែលមានចិត្តធម៌ ផ្សាយដំណឹងល្អ ព្រះយេស៊ូគ្រីស្ត ។
- សូមព្រះប្រទាន នូវព្រះវិញ្ញាណ ដ៏ភ្លឺត្រចះ ជូនដល់អ្នកម្ដាយ
  ប្រសើរវិសេស សូមជួបប្រទះ សុខសាន្តតទៅ ។
- ដើម្បីបន្ត ផ្សាយដំណឹងល្អ នឹងណែនាំផ្លូវ ដល់អស់ប្រជា
  អោយចេះរស់នៅ មានចិត្តត្រឹមត្រូវ ដោយក្ដីមេត្តា ។
- ពិសេសខ្ញុំសូម នឹងគោរពជូន ដល់អ្នកនាំសារ សូមលោកទាំងអស់
  សុខគ្រប់ប្រការ កំលាំងខ្លាំងខ្លា ប្រាជ្ញារឿងអើយ ។
- នេះវាចារខ្ញុំ ដែលបានរៀបចំ ជូននាំសារហើយ បទកាកគតិ
  ទុកជាចម្លើយ ខុសត្រូវសូមឆ្លើយ ទៅលេខក្រោយទៀត ។ ***គង់ សាវ៉ាន់***

## ព្រះសហគមន៍កើតថ្មីនៅ,,,

ដូចមុនដែរ។ ដោយគ្មាននរណាជួយដល់ពួកគេ ពូធឿនបានទៅទាក់ទងនឹងព្រះសហគមន៍កំពង់ចាម ដោយបានរៀបរាប់ពីការចង់ស្វែងយល់ពីព្រះបន្ទូល របស់បងប្អូនប្រាប់លោកឳពុកអន់តូនី ធ្វើអោយលោកអារម្មណ៍យ៉ាងខ្លាំងចំពោះក្រុមនេះ ហើយបានចាត់លោកយាយម្នាក់នៅខេត្តស្វាយរៀងអោយទទួលខុសត្រូវនៅកន្លែងនោះ។ លោកឳពុកបានបញ្ជូនមនុស្សពីរបីនាក់ទៅជួយអប់រំបន្ថែមផ្នែកសង្គម។ បងប្អូនទាំងនោះជួបជុំគ្នានៅផ្ទះរបស់លោក ពូធឿន រហូតសព្វថ្ងៃនេះ។

ដោយចំនួនមនុស្សកើនឡើងនៅផ្ទះរបស់លោកពូធឿន ពុំមានកន្លែងល្មមសំរាប់ជួបជុំគ្នាទៀត ដូច្នេះពួកគេ បានសុំអោយមានកន្លែងមួយសំរាប់ជួបជុំគ្នា។ ដោយឃើញពួកគេទាំងអស់គ្នាកាន់តែមានជំនឿយ៉ាងខ្លាំងចំពោះព្រះបន្ទូលព្រះជាម្ចាស់ នឹងចង់ក្លាយខ្លួន ជាគ្រីស្តបរិស័ទ លោកឳពុក បងស្រីបានសំរេចបង្កើតអោយមានព្រះសហគមន៍នៅទីនោះ ដោយអោយឈ្មោះថាព្រះសហគមន៍ "ក្ដីបឹងឬប្រាសាទ"។ ព្រះសហគមន៍" ក្ដីបឹងរឺ "ប្រាសាទ" បានកើតឡើងនៅខែ តុលា ឆ្នាំ ២០០២។ រាល់ថ្ងៃសៅរ៍-អាទិត្យមានបងប្អូនស្វែងយល់ មកជួបជុំគ្នា រៀបចំពីធីបុណ្យ អធិដ្ឋានហាត់ចំរៀង គេមិនទាន់បានទទួលអប់រំជំនឿស៊ីជំរៅនៅឡើយទេក្រុមនោះមានគ្នាប្រហែល ៤០ ទៅ ៥០នាក់ ហើយគេបានរៀបចំក្រុមពីរគឺក្រុមសង្គហៈនិងក្រុមពិធីបុណ្យ។ ***ពិឈិញ***

## ក្ដីសង្ឃឹមថ្មីរបស់ព្រះសហគមន៍

កាលពីថ្ងៃទី ២ កុម្ភៈ ២០០៤ មានការចុះហត្ថលេខារបស់ក្រសួងអប់រំទទួលស្គាល់ វិទ្យាល័យសន្តហ្វ្រង់ស័រ នៃព្រះសហគមន៍ចំការទៀងជាវិទ្យាល័យក្រៅក្របខ័ណ្ឌរដ្ឋ។ នេះជាមោទនភាពរបស់ព្រះគមន៍ចំការទៀង ដែលមានលោកឳពុក **អូលី វីយ៉េ** ជាអ្នកទទួលខុសត្រូវ និង លោក **អេមីល ដេតម្ប** ជាអភិបាលក្នុងភូមិភាគនេះ ក៏ដូចជាព្រះសហគមន៍នៅប្រទេសកម្ពុជាទាំងមូលដែរ។ តាមប្រសាសន៏របស់លោកឳពុក អូលី វីយេ បានអោយដឹងថា "នេះជាឱកាស មួយដ៏ប្រសើបំផុត ដែលបើកផ្លូវសំរាប់ព្រះសហគមន៏ក្នុងពេលអនាគត់ក្នុងការអភិវឌ្ឍន៏ផ្នែកវិស័យអប់រំនេះ "។

សូមបញ្ជាក់ផងដែរថា វិទ្យាល័យសន្ត ហ្វ្រង់ស័រ ជាវិទ្យាល័អប់រំចំណេះទូទៅ ទី ១ របស់ព្រះសហគមន៏កាតូលិកនៅកម្ពុជា។ ***វណ្ណា***

# វិធីទាំង៧ក្នុងការអធិដ្ឋាន

ដកស្រង់ចេញពីវីដេអូដែលមានឈ្មោះថា seven circle of prayer ដែលចេញផ្សាយដោយ CAHAYA SUARA RESOURCE CENTRE ពីទីក្រុងកូឡាឡាំពួរ ហើយបកប្រែជាភាសាខ្មែរ ដោយបងស្រី សង្វាត នឹង បងស្រី ថារីន ក្រុមគ្រួសារស្រលាញ់ព្រះឈើឆ្កាង។ **តពីលេខមុន**

## ៤-ទុក្ខលំបាក

នៅក្នុងជំហានទី ៤ នៃការអធិដ្ឋាន បងប្អូននឹងជួបប្រទះនូវទុក្ខលំបាក។ ពេលបងប្អូនចូលយ៉ាងស៊ីជំរៅក្នុងការអធិដ្ឋានគឺត្រូវការលះបង់ខ្លួន។ បងប្អូនដឹងច្បាស់ថាការអធិដ្ឋានត្រូវការទីកន្លែង និងភាពស្ងៀមស្ងាត់ហើយកាន់តែយល់ច្បាស់ឡើងពេលដែលបងប្អូនចូលទៅក្នុងទីកន្លែង ងងឹត ។

សេចក្តីទុក្ខព្រួយ (ទុក្ខលំបាក) គឺស្ថិតនៅក្នុងភាពឯកា និងភាពស្ងៀមស្ងាត់។ បងប្អូនត្រូវការពិចារណាពីអាថ៌កំបាំងនៃទុក្ខលំបាកនោះ។ មានបងប្អូនខ្លះអាចនិយាយពីទុក្ខលំបាករបស់ខ្លួនបានដើម្បីអោយបងប្អូនឯទៀតស្តាប់គេ។ ឯខ្លះទៀតមិនអាចនិយាយបានទេ ដោយគេរកមិនឃើញពីមូលហេតុរបស់វា រីក៏បងប្អូនខ្លះទៀតអាចរក ឃើញមូលហេតុនិងអាចនិយាយបានតែមិននិយាយចេញអោយគេឯងដឹងឡើយ។ ពេលខ្លះបងប្អូន ចូលក្នុងទីងងឹតពេលយប់ម្នាក់ឯងបងប្អូនងាយនឹងទទួលអារម្មណ៍ខ្វល់ខ្វាយជាទុក្ខលំបាករបស់មនុស្សដែលនៅជុំវិញខ្លួនយើង រឺបងប្អូនឯទៀត។ ប៉ុន្តែយើងគ្មានពេលវេលាល្មមដើម្បីនៅស្ងៀមស្ងាត់ និងនៅក្នុងទីងងឹតស្តាប់នូវសេចក្តីសោកសង្រេងនិងទុក្ខលំបាក របស់បងប្អូនឯទៀតបានឡើយ ។

ទាំងបងប្អូន និង ខ្ញុំ ដឹងហើយថានៅក្នុងពិភពលោកនេះ ពោរពេញទៅដោយការស្រេកឃ្លាន និងការឈឺចាប់ ប៉ុន្តែអ្វីទាំងនេះមានតែនៅក្នុងខួក្បាលរបស់ យើងតែប៉ុណ្ណោះ ។ ពាក្យថា "ទុក្ខវេទនា" បានចងយើងអោយប្រឆាំងនឹងអារម្មណ៍របស់ខ្លួនជាប់។ វាពិបាកណាស់នៅពេលយើងនិយាយពីអារម្មណ៍ទុក្ខលំបាក ធ្វើអោយទាស់នឹងសេចក្តីសុខក្នុងចិត្តរបស់យើង។ យើងគ្រប់គ្នាសុទ្ធតែទទួលនូវសមុទ្រទុក្ខរបស់មនុស្សទាំងអស់គ្នា ។ ប៉ុន្តែ




បងប្អូននិងខ្ញុំចាប់អារម្មណ៍តែពីទុក្ខលំបាករបស់ខ្លួនឯងច្រើន ជាងទុក្ខលំបាកបងប្អូនឯ ទៀតៗ ។

**បញ្ហារបស់បងប្អូនឯទៀតមិនសំខាន់ជាងបញ្ហារបស់ខ្ញុំឡើយ ។**

**តើធ្វើដូចម្តេចដើម្បីអោយខ្ញុំ ទទួលយកនូវទុក្ខលំបាកទូទៅ ចូលក្នុងការអធិដ្ឋានរបស់ខ្លួនបាន ?**

**តើធ្វើដូចម្តេច ដើម្បីអោយខ្ញុំទទួលយកនូវទុក្ខលំបាកទាំងនេះមកក្នុងជីវិតរបស់ខ្ញុំបាន ?**

សូមអង្វរព្រះជាម្ចាស់សូមទ្រង់បើកភ្នែក ដួងចិត្តរបស់បងប្អូនអោយមើលឃើញកាន់តែច្បាស់ឡើងៗ នូវទុក្ខលំបាកក្នុងភាពស្ងៀមស្ងាត់ ។

នៅក្នុងនេះដែរ ទុក្ខលំបាក គឺការមិនទទួលស្គាល់របស់មនុស្ស។ សូមអង្វរព្រះជាម្ចាស់ សូមព្រះអង្គបង្ហាញនូវមូលហេតុដែលធ្វើអោយបងប្អូនបិទដួងចិត្ត សូមព្រះអង្គបង្ហាញអោយបងប្អូន ឃើញពីភាពលំអៀងរបស់ខ្លួន ហើយភាពលំអៀងនោះបានធ្វើអោយរាំងស្ទះ បងប្អូនមិនអោយស្តាប់នូវទុក្ខលំបាករបស់អ្នកដទៃនិងសូមអោយបងប្អូនចេះចូលរួមជាមួយ បងប្អូនឯទៀតៗ ផង។ អោយបងប្អូនបានស្គាល់នូវអាថ៌កំបាំង ដែលធ្វើអោយបងប្អូន មិនចេះស្តាប់បងប្អូនឯទៀតៗនោះ។ សូមព្រះអង្គបង្ហាញអោយបងប្អូននូវអាថ៌កំបាំងនៃការភ័យខ្លាច ដែលបងប្អូនមានចំពោះអ្នកឯទៀតៗ។ សូមព្រះអង្គជួយអោយបងប្អូនចេះបើកចិត្តទទួល បងប្អូនមិនត្រឹមតែបងប្អូនដែលជិតខ្លួននោះឡើយ គឺបងប្អូនដែលនៅឆ្ងាយ (មិនសូវ ជិតស្និទ្ធ) ផងដែរ ។

សូមកុំភ័យខ្លាចអ្វីឡើយនៅក្នុងការអធិដ្ឋាន សូមព្យាយាមទូលអង្វរព្រះជាម្ចាស់ផ្ញើសេចក្តីទាំងនេះទៅព្រះអង្គ។ សូមពិចារ ណាចំពោះអ្នកស្រេកឃ្លាន ជនឯកោ និងអ្នកភ័យខ្លាច។ ព្រះជាម្ចាស់ ត្រូវការបងប្អូនយក ចិត្តទុកដាក់ចំពោះបងប្អូនទាំងនោះ។ **"អស់អ្នកដែលស្រេកឃ្លាន នឹង បានឆ្អែតរីងអ្នក ក្រខ្សត់នឹងបានទទួល ព្រះរាជ្យរបស់ព្រះ ជាម្ចាស់"**

ដូច្នេះពេលបងប្អូនអធិដ្ឋានសូមចំណាយពេលវេលា ក្នុងជំហាននៃទុក្ខលំបាក នេះដោយបើកចិត្តអោយទូលំទូលាយ ដើម្បីទទួលបងប្អូនដែលមានទុក្ខព្រួយអស់សង្ឃឹមសូមពិចារណា នូវសេចក្តីសោកសង្រេងរបស់គេអោយដូចជាទុក្ខព្រួយរបស់បង ប្អូនផ្ទាល់។

***នៅមានត***

អ្នកនាំសារ

**ក្រុមនិពន្ធ**
គឹម រតនា, គឹម សំអាត
**រូបភាព :** គុយរិន , Amadeus
**កុំព្យូទ័រ :** លី សុវណ្ណា
ការិយាល័យផ្សព្វផ្សាយពត៌មានព្រះសហគមន៍កាតូលិក
Nº 787, Monivong Blvd,
Phnom Penh-CAMBODIA
Tel/Fax : (855) 23 726 197
E-mail : cscmediacenter@bigfoot.com
អភិបាលគ្រប់គ្រង
លោកអភិបាល អេមីល ដេតម្ប
អគ្គនាយក
លោកបូជាចារ្យ អូមែរ ហ្សីវ៉ាល់ដូ

# ព្រះអំណោយទានពិសេសរបស់ព្រះជាម្ចាស់

ក្នុងឱកាសបុណ្យណូអែលកន្លងទៅនោះ អ្នកានាំសារបានជួបសម្ភាសន៍ជាមួយលោកពូ ស៊ីនួន មាន អាយុ ប្រហែល ៣០ឆ្នាំ ជាជនជាតិភាគតិច(ព្នង) នៅ ភូមិប៊ូស្រា ខេត្ត មណ្ឌលគិរី ។ លោកពូស៊ីនួន ពិការភ្នែក ទាំងសងខាង លក្ខណៈនេះធ្វើអោយពិបាកក្នុងការរស់នៅ ទោះជាយ៉ាងណាក៏ដោយក៏លោកពូនៅតែមានអំណេរសប្បាយក្នុងការរស់នៅដែរ។ "មានបងប្អូនជាច្រើនស្រលាញ់ ចូលចិត្តគាត់យ៉ាងខ្លាំងមិនថាចាស់ ឬ ក្មេង ឡើយ" នេះបើតាមសំដីអ្នកជិតខាង។

ពិតមែនតែលោកពូពិកាភ្នែកមើលអ្វីពុំឃើញ តែលោកពូមានអំណោយទានមួយពិសេស គឺចេះលេងភ្លេងយ៉ាងពីរោះដែលធ្វើអោយបងប្អូនទាំងអស់កោតសសើរនូវសំលេងភ្លេងដ៏ពិរោះនេះ ។ ជាងនេះទៅទៀតនោះគឺឧបករណ៍ដែល គាត់លេងនេះមិនមែនជាអ្វីអស្ចារ្យនោះទេ ប៉ុន្តែអ្វីដែលប្លែកនោះគឺគាត់ធ្វើដោយខ្លួនគាត់ផ្ទាល់។ ឧបករណ៍នោះធ្វើ អំពីឬស្សី កំប៉ុងផ្សេងៗ នឹងខ្សែលីឡុងដែលអចលេងបានដូចហ្គីតា តែវាមានសំលេងផ្សេងពី ហ្គីតា។

ពិតមែនតែលោកពូពីការតែលោកពូអាចមានសមត្ថភាពដ៏ប្រសើ នេះក៏ដោយសារព្រះអំណោយទានពិសេសពីព្រះជាម្ចស់ធ្វើអោយចេះលេងភ្លេងយ៉ាងពិរោះ និងមានបងប្អូនជាច្រើនស្រឡាញ់រាប់អាន ។

ក្នុងការរស់នៅរបស់លោកពូគឺពោរពេញដោយសេចក្ដីសង្ឃឹមជានិច្ច ដូច្នេះហើយសូមយើងជួយលើកស្ទួយដល់ជនពិការ ដើម្បីអោយជីវិតរបស់គេមានតំលៃដ៏ប្រសើរដូចមនុស្សធម្មតាដែរ ទោះជាគេមិនមានលក្ខណៈពេញលេញដូចយើងក៏ដោយ តែគេមានសមត្ថភាព និង គំនិតបញ្ញាស្មារតី ច្នៃប្រឌិតដូចយើងធម្មតាដែរ។



បងស្រីរួមជាមួយពូ ស៊ីនួន

ជនពិការក៏ដូចយើងដែរព្រះជាម្ចាស់បានប្រទានអំណោយទានពិសេសសំរាប់គេ ដើម្បីអោយគេមានសេចក្ដីសង្ឃឹមក្នុងការ រស់នៅ។ ដូចនេះហើយយើងគួចេះគោរពនូវអ្វីដែលបានទទួលព្រះជាម្ចាស។

***អ្នកនាំសារកំពង់ចាម***

